# ជំនួបពិភាក្សាសម្ដែងការគួរសម រវាង ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយ លោក Ingo Karsten ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា ដែលទើបតែងតាំងថ្មី



នារសៀលថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧ នៅទីស្ដីការ ក្រសួង លោកឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនលើគ្រប់វិស័យរបស់កម្ពុជា ជាពិសេសជាប្រទេសដែលសម្បូរណ៍ដោយ ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌រុងរឿង ដែលពោរពេញដោយប្រាសាទបុរាណ និងរម្មណីដ្ឋានប្រវត្តិសាស្ត្រជាច្រើន និងរិតតែពិសេសទៅទៀតនោះគឺកម្ពុជាមានស្ថេរភាពនយោបាយ សុខសន្តិភាព និងសេដ្ឋកិច្ចទីផ្សារសេរីគួរឲ្យចាប់អារម្មណ៍។ នេះបើតាមការសង្កេត និងការធ្វើដំណើរទស្សនៈកិច្ចដោយផ្ទាល់ តាមបណ្ដាខេត្តមួយចំនួន តែក្នុងរយៈពេលខ្លី ដែលលោកទើបមកបំពេញបេសកកម្មការទូតនៅកម្ពុជាប៉ុណ្ណោះ។

ចំណុចទាក់ទាញនេះ លោកនឹងមិនភ្លេចទេ ជម្រាបដល់ក្រុមវិនិយោគិន ធុរៈជនក៏ដូចជាឧស្សាហាករ អាល្លឺម៉ង់ឲ្យចាប់អារម្មណ៍ បណ្តាក់ទុននៅកម្ពុជាឲកាន់តែច្រើនថែមទៀត។ ជាមួយគ្នានេះ លោកឯកអគ្គរដ្ឋទូតក៏បានជម្រាបដំណឹងផងដែរថា នៅដើមខែកុម្ភៈខាងមុខនេះ នឹងមានប្រតិភូសភាអាល្លឺម៉ង់ រួមជាមួយអ្នកវិនិយោគ មួយក្រុមនឹងអញ្ជើញមកទស្សនកិច្ចនៅកម្ពុជា ដោយផ្តោតជាសំខាន់នៅទីរួមខេត្តសៀមរាប ដែលជាខេត្តមានសក្តានុពលខ្ពស់លើវិស័យទេសចរណ៍។ តែទោះជាយ៉ាងណា ក្នុងជំនួបពិភាក្សានេះ **លោក Ingo Karsten** នៅតែចង់បានអនុសាសន៍ចង្អុល បង្ហាញមួយចំនួនពី **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ទាក់ទងលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មនៅកម្ពុជា ដោយយោងលើបទពិសោធន៍ យូរឆ្នាំរបស់លោក ទេសរដ្ឋមន្ត្រីផ្ទាល់។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានសម្តែងការស្វាគមន៍ និងសង្ឃឹមថា តាមរយៈបេសកកម្មការទូតរបស់**លោក Ingo Karsten** នៅកម្ពុជាប្រទេសទាំងពីរ កម្ពុជា-អាល្លឺម៉ង់ នឹងពង្រឹងពង្រីកថែមទៀត នូវទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការ កាន់តែប្រសើរឡើង។ ទាក់ទងវិស័យឧស្សាហកម្ម លោកសង្ឃឹមថា នឹងទទួលបានកិច្ចសហការល្អពីភាគីអាល្លឺម៉ង់ទាក់ទងនិងការផ្ទេរបច្ចេកវិទ្យាថ្មីៗតាមរយៈការ បណ្តាក់ទុនវិនិយោគ ក៏ដូចជាការពង្រឹងសម្ថភាពតាមរយៈ ការបណ្តុះបណ្តាលធនធានមនុស្សជាដើម។ ចំណុចនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានជម្រាបជូនថា នៅសប្តាហ៍ទី៣ នៃខែនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងការិយាល័យប្រកាសនីយបត្រតក្កកម្ម នៃសហគមន៍អឺរ៉ុប ( European Patent Office) នឹងចុះអនុស្សារណៈយោគយល់គ្នា ស្តីពីការចុះបញ្ជីទទួលស្គាល់គ្នាទៅវិញទៅមក រវាងសហគមន៍អឺរ៉ុប និងកម្ពុជា សម្រាប់កិច្ចការពាររបបគំហើញស្នាដៃតក្កករ ដែលមានផល ប្រយោជន៍សម្រាប់ដំណើការផលិតកម្ម ក្នុងវិស័យបច្ចេកវិទ្យា ដែលជាចំណុចដ៏សំខាន់មួយសម្រាប់ការទាក់ទាញ វិនិយោគផ្នែកបច្ចេកវិទ្យា និងរបបគំហើញថ្មីៗពីសហគមន៍អឺរ៉ុបមកកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានកោតសរសើរថា ថ្វីត្បិតលោកអគ្គរដ្ឋទូតទើបមកបំពេញបេសកកម្មការទូត នៅកម្ពុជា ក្នុងរយៈពេលខ្លី តែលោក បានយល់ពីសភាពការណ៍កម្ពុជាបានច្រើន។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់បន្ថែមនូវចំណុចជាសក្តានុពលរបស់កម្ពុជា គឺទន្ទឹមនិងកម្ពុជា ទទួលបានសុខសន្តិភាពទូទាំងប្រទេស មានស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច គឺកម្ពុជាមានរបបសេដ្ឋកិច្ចទីផ្សារសេរី មានការលើកទឹកចិត្តច្រើន ចំពោះការវិនិយោគផ្ទាល់ពីក្រៅប្រទេស ជាពិសេស

គឺភាពអនុគ្រោះពាណិជ្ជកម្ម ដែលកម្ពុជាទទួលបាន ពីបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសដៃគូជាច្រើន ក្នុងនាមកម្ពុជា ជាប្រទេសអភិវឌ្ឍតិចតួច និង ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួន ចូលក្នុងតំបន់និងពិភពលោក។

ដោយឡែក ក្រោមក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលមានលំហូរដោយសេរីនូវទំនិញ ការវិនិយោគ និងមូលធនជាដើម លោកទេសរដ្ឋមន្ត្រី បានជម្រាបជូនថា កម្ពុជាស្ថិតចំកណ្តាលបេះដូងអាស៊ាន ការផលិតទំនិញគ្រប់យ៉ាង ដូចជាគ្រឿងបង្គុំរថយន្ត និងគ្រឿងចក្រផ្សេងៗ ពិតជាមានអត្ថប្រយោជន៍ ដែលលោកស្នើឲ្យភាគីអាល្លឺម៉ង់ចាប់អារម្មណ៍លើចំណុចនេះ ខណៈដែលបច្ចេកវិទ្យាអាល្លឺម៉ង់ មានការទទួលស្គាល់ពេញពិភពលោក ។ ជាក់ស្តែងទីផ្សាររថយន្តអាល្លឺម៉ង់ កំពុងមានការពេញនិយម នៅកម្ពុជា។ លោកទេសរដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមថា ការផលិតនៅកម្ពុជាមិនត្រឹម សម្រាប់លក់រួចពន្ធនៅទីផ្សារអាស៊ានប៉ុណ្ណោះទេ តែទៅកាន់ទីផ្សារពិភពលោក ជាច្រើនទៀត តាមរយៈភាពអនុគ្រោះពាណិជ្ជកម្ម និងកម្ពុជា ជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO)។

ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** ក៏បានជម្រាបជូន ពីគោលដៅចម្បងនៃការអភិវឌ្ឍ វិស័យឧស្សាហកម្ម តាមរយៈគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ២០១៥-២០២៥ និងគំនិតផ្តួចផ្តើម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការបង្កើតតំបន់ចង្កោមសហគ្រាសខ្នាតតូច និងមធ្យម (SMEs Cluster Zone) ដើម្បីលើកកំពស់ វិស័យសហគ្រាសខ្នាតតូច និងមធ្យមផង និងគាំទ្រដល់សង្វាក់ផលិតកម្មនៃឧស្សាហកម្ម ធុនមធ្យម និងធុនធ្ងន់ផង៕



